## ៣

# ហេតុអ្វីបានជាខ្ញុំចាកចេញពីក្រុងភ្នំពេញ

ក្នុងអំលុងទសវត្សទី៦០, ធ្ងន់កាត់ស្ថានភាពមួយថ្ងៃកាត់មួយថ្ងៃកោរ, ភាពតានតឹងទាំងក្នុងសង្គមខ្មែរ និងក្រៅប្រទេសកាន់តែកើនជាលំដាប់ ។

នៅក្នុងប្រទេស, ការបែកបាក់រវាងនិន្នាការនៃមតិសាធារណៈទាំងពីរបក្ស រិតតែកើនឡើងជាលំដាប់ ជាពិសេសរវាងអ្នកគាំទ្រនិងអ្នកប្រឆាំងនឹងនយោបាយអព្យាក្រិតរបស់សម្ដេច ។ ឯវិបត្តិសេដ្ឋកិច្ចនិង សង្គមរិតតែធ្ងន់ធ្ងរទៅៗ ។ នៅក្នុងទីក្រុង ឧស្សាហកម្មដែលតូចតាចខ្សត់ខ្សោយស្រោប់ ក៏ត្រូវរលំអស់ នៅពេលដែលចំនួនប្រជាជនកាន់តែកើនឡើងជាលំដាប់ដោយព្រោះតាមជនបទនានាភាពក្រីក្រកាន់តែ គ្រប់ដណ្ដប់គំរាមកំហែងការរស់នៅរបស់គេ និង ម្យ៉ាងទៀតពួកគេហាក់ទាក់ទាញដោយជីវិតទំនើបនៃ ពួកក្រុមស្រទាប់សង្គមលំដាប់ខ្ពស់មួយក្ដាប់តូច ។

ព្រមពេលជាមួយគ្នានោះ ការរីករាលដាលនៃសង្គ្រាមវៀតណាម ធ្វើឲ្យសម្ដេចធ្លាក់នៅក្នុងស្ថានភាព មួយរិតតែពិបាកទៅៗ ។

ចាប់ពីឆ្នាំ១៩៦៥ ដើម្បីជៀសផុតពីប្រតិបត្តិការណ៍បោសសំអាត និង ការទម្លាក់គ្រប់បែកជាប្រពល របស់កងទ័ពអាមេរិកនិងវៀតណាមខាងត្បូង, ពួកក្រុមយួនខាងជើងក៏បានរត់មកលាក់ខ្លួន ពួនអាត្មា ពាសពេញតំបន់មួយចំនួននៃដែនដីប្រទេសយើង គឺ តាមបណ្ដោយព្រំប្រទល់ខាងជើង ។ សម្ដេច គ្មានជម្រើសអ្វី ក្រៅពីទទួលអនុគ្រោះឲ្យពួកយួនទាំងនោះទេ ។

មួយឆ្នាំក្រោយមក, នៅពេលដែលអាមេរិកាំងបិទផ្លូវតាមឆ្នេរសមុទ្រ និង បង្កើតការទម្លាក់គ្រាប់បែក តាមផ្លូវលំហូជីមិញ, ការដឹកជញ្ជូនគ្រឿងភស្តុភាសម្រាប់ចលនាតស៊ូរបស់យួនមានការលំបាកជាខ្លាំង ឃើញដូច្នោះសម្ដេចក៏អនុញ្ញាតិឲ្យប្រើប្រាស់កំពុងផែក្រុងសីហនុ សម្រាប់ដឹកជញ្ជូនគ្រឿងអាវុធ យុទ្ធភ័ណ្ឌនិងភស្តុភាផ្សេងៗ ដើម្បីផ្គត់ផ្គង់កម្លាំងចលនាតស៊ូរបស់យួន ។ សម្រាប់សម្ដេច, ទាំងនេះ គឺជា គ្រោះថ្នាក់ដែលបានគិតទុកជាមុន ។ ជំនួយលួចលាក់ដែលសម្ដេចផ្ដល់ឲ្យក្រុងហាណូយ គឺជា ការរំលោភដល់នយោបាយអព្យាក្រិតរបស់ព្រះអង្គដែលមិនអាចក្រកែកបានឡើយ ហើយអំពើនេះ នឹងផ្ដល់ផលអាក្រក់ជាច្រើនដល់ព្រះអង្គទាំងក្នុងនិងក្រៅប្រទេស ។ ប៉ុន្ដែកង្វល់របស់ព្រះអង្គនាពេល នោះគ្មានអ្វីក្រៅពីជួយចលនាតស៊ូរបស់យួនឲ្យទប់ទល់នឹងកម្លាំងអាមេរិកាំង ជៀសវាងកុំឲ្យសង្គ្រាម នេះរីកដាលជ្រៅចូលក្នុងដីខ្មែរ ។ ព្រះអង្គក៏បានគិតផងដែរថា កម្លាំងវៀតណាមមុខតែឈ្នះ ដូច្នេះបើ ព្រះអង្គចាប់យកវៀតណាមទៅ ដល់ពេលគេឈ្នះ គេនឹងដឹងគុណព្រះអង្គ នោះនឹងនាំឲ្យទំនាក់ទំនង នៃប្រជាជាតិទាំងពីរមានដំណើរការប្រសើរជាមិនខាន ។

©រក្សាសិទ្ធិគ្រប់យ៉ាង

http://www.amekhmer.org

គ្រោះចង្រៃ, ការដឹកជញ្ជូនគ្រឿងកស្តុភាអាវុធយុទ្ធភ័ណ្ឌសម្រាប់ផ្គត់ផ្គង់កងទ័ពកុំម្មុយនីសយួនតាមក្រុងសីហនុទាំងនោះបែរជាផ្តល់ឱកាសឲ្យមានអំពើររត់ពន្ធដ៏ខ្មៅកខ្វក់ទៅវិញ ដែលបណ្តាលឲ្យកើតអស្ថេរភាពជាខ្លាំងចំពោះសេដ្ឋកិច្ចរបស់យើង ដែលកំពុងទន់ខ្សោយស្រាប់ ។ ហិរញ្ញវត្ថុជាតិ ត្រូវរីងក្រោះឈាម ដោយសារតែការរត់ពន្ធគគ្រឹកគគ្រេង នូវ អង្ករ, គ្រឿងឧបភោគបរិភោគផ្សេងៗ ។ លោក វីលីយាំ ហ្សូវគ្រូស បានសរសេរពីបញ្ហានេះដូចតទៅ ៖

"ចាប់ពីពេលនោះមក(១៩៦៦)រហូតដល់ឆ្នាំ១៩៧០ មានកប៉ាល់ជាច្រើនបានផ្ទុកគ្រឿងកស្តុភារ និង គ្រឿងសព្វាវុធ មកស្តុកនៅកំពុងផែ ។ បន្ទាប់មករបស់ទាំងនោះត្រូវពួកកងទ័ពខ្មែរ និង ក្រុមហ៊ុនចិនមួយឈ្មោះ "ហាឃ្វី" ទទួលដឹកជញ្ជូនបន្តទៅទៀត តាមក្បួនឡានកាំមីញ៉ុងផ្ទុកទំនិញ ដែលចេញដំណើរនៅពេលយប់ តាមផ្លូវមិត្តភាពដែលជាជំនួយរបស់អាមេរិកកាំង កាត់តាមទីក្រុងភ្នំពេញសំដៅទៅទិសខាងកើត ឆ្ពោះទៅកាន់ព្រំប្រទល់ខាងកើត ។ ការរកស៊ីដឹកជញ្ជូននេះ រួមជាមួយការរកស៊ីលក់ផ្ទាល់តាមទីផ្សារនានានៅទីក្រុងភ្នំពេញ នូវ ស្បៀង ថ្នាំសង្កូវ ផងនោះ នាំឲ្យឈ្មួញកណ្តាល បានចំណេញកប់ក្តោង ។

វាជាការមួយគួរឲ្យហួសចិត្ត ដែលលោក លន់-នុល, ដៃម្ខាងបិទបាំង(ឬក៏បានចូលរួមផង)នឹងអំពើរត់ពន្ធនោះ ឯដៃម្ខាងទៀតប្រមែប្រមូលមិនត្រឹមតែពួកក្រុមមានអំណាចមួយចំនួនដែលនៅនឹកអាលោះអាល័យ នឹង ជំនួយអាមេរិកកាំងនោះទេ តែក៏មានពួកក្រុមវណ្ណការតូចតាចរហូតដល់ពួកក្រុមបញ្ញវ័នមួយចំនួនដែលកាន់តែព្រួយបារម្ភណ៍ឡើង ដោយព្រោះតែឃើញអំពើពុករលួយរាលដាលពេញស្រុក ដើម្បីប្រឆាំងនឹងនយោបាយអព្យក្រិតរបស់សម្តេច ។ ដូច្នេះក៏មានការតិះទៀនមិនចំហរចំពោះព្រះអង្គ និងពាក្យអាស្រូវផ្សេងៗទៀតពីអំពើពុករលួយរបស់ក្រុមរាជវង្សានុវង្សល្បីរន្ទឺពេញទីក្រុងភ្នំពេញ។

ជាមួយនឹងការត្រូវជ្រើសរើសសភាថ្មីខិតចូលមកដល់ នៅពេលដែលសម្តេចជាប់កុនដោយពាក្យស្នើសុំឲ្យសម្តេចឲ្យឈរឈ្មោះជាបេក្ខជននោះ ស្រាប់តែមានពាក្យចចាមអារ៉ាមថា សម្តេចបានធ្វើអន្តរាគមន៍ផ្ទាល់ក្នុងការជ្រើសរើសបេក្ខជននាពេលជ្រើសរើសសភាមុនៗ សម្តេចក៏មិនហ៊ានធ្វើដូចពេលមុនៗទៀតទេ ហើយក៏សម្រេចចិត្តទុកបញ្ជីចំហដល់សមាជិកសង្គមរាស្ត្រនិយមទាំងអស់ ។ តើព្រះអង្គនឿយណាយនឹងពាក្យតិះទៀនទាំងនោះ ឬ ក៏ព្រះអង្គមានបំណងចង់ជៀសវាង ការផ្ទេរសិទ្ធិពួកមនុស្សដែលស្មោគ្រស្មោះនឹងព្រះអង្គចេញ ។ ក្នុងស្ថានភាពបែបនេះ បើព្រះអង្គជ្រើសរើសម្នាក់ហើយបដិសេធម្នាក់ទៀតដែលនៅក្នុងក្រុមបក្សតែមួយ នោះប្រាកដជាមានការឈ្លោះទាស់ទែងគ្នាជាមិនខាន ។ ទោះបីដោយប្រការណាមួយ ការទាំងនេះក៏ជាកំហុសដ៏ធំធេងរបស់ព្រះអង្គដែរ ដែលបានបណ្តាយឲ្យមានផលវិបាកដ៏ធ្ងន់ធ្ងរដល់ព្រះអង្គ និង ដល់ប្រទេសជាតិទាំងមូល ។ ជាការពិតយូរយារណាស់មកហើយ ដែលលោក លន់-នុល បានជ្រកក្រោមផ្ទាក "សង្គមរាស្ត្រនិយម" ដោយ

យកលេសថា តស៊ូប្រឆាំងនឹងកុំម្មុយនិស្ត តែព្យាយាមរៀបចំគម្រោងការក្រោយខ្នងសម្តេច ដើម្បីការឡើងកាន់អំណាចដោយផ្ទាល់ខ្លួន ។

លោក លន់-នុល បានប្រមែប្រមូលពួកចៅហ្វាយខេត្ត ចៅហ្វាយស្រុក មេឃុំមកខាងគាត់ស្ទើរតែទាំងអស់ ។ តាមការពិត សភាដែលបានមកពីការជ្រើសរើស"សេរី" នាឆ្នាំ១៩៦៦នោះ គឺជាឧបករណ៍របស់គាត់ទាំងអស់ គឺ សភានោះហើយដែលបានបោះឆ្នោតជា"ឯកច្ឆ័ន្ទ" ទម្លាក់សម្តេច នៅពេល៤ឆ្នាំក្រោយមក ។

ទម្រាំតែគាត់អាចក្លាយទៅជាប្រមុខរដ្ឋ លោក លន់-នុល ព្យាយាមសុំឲ្យសម្តេចយល់ព្រមចាត់តាំងគាត់ឡើងជា "គណៈកម្មាធិការរដ្ឋសម្រាប់ប្រមូលស្រូវ" ដោយយកលេសថា ដើម្បីធ្វើការប្រយុទ្ធប្រឆាំងនឹងការរត់ពន្ធស្រូវអង្ករ ក្នុងទិសដៅបញ្ចប់ការហូរខ្សោះឈាមនៃហិរញ្ញវត្ថុជាតិ ។ ការពិតគណៈកម្មាធិការទាំងនេះគ្រាន់តែជាឧបករណ៍ដែលគេបានរៀបចំទុកមកជាយូរហើយ សម្រាប់បង្កើនការគាបសង្កត់ ។

ការបង្ក្រាបដ៏កម្រាលនៅសំឡូតក្នុងខេត្តបាត់តំបង នាពេលដែលប្រជាកសិករនាំគ្នាបះបោរប្រឆាំងនឹងការរឹបអូសដីធ្លីរបស់គេ ដោយពួកមេទាហានមួយចំនួន ។ ចំពោះបញ្ហានេះលោក វីលីយាំ-ហ្សូវក្រូស បានសរសេរដូចតទៅ ៖ "ការបង្ក្រាបបានប្រព្រឹត្តិទៅដោយការបង្ហូរឈាម, ភូមិករណ៍ត្រូវគេបំផ្លាញខ្ទេចខ្ទី និង ប្រជាជនត្រូវគេវាយធ្វើបាបរហូតដល់ស្លាប់ ។ ប្រជាកសិករ រាប់រយនាក់បានរត់កៀសខ្លួនទៅតស៊ូ ទាំង គុំនំនៅជាប់ក្នុងចិត្ត" ។

ចំណែកឯលោក ដាវិដ-ឆាន់ល័រ បានសរសេរពីព្រឹត្តិការណ៍នេះដូចតទៅ ៖ "ប្រតិបត្តិការណ៍បោសសំអាតជុំវិញសំឡូតប្រព្រឹត្តិទៅអស់ជាច្រើនខែ ។ ការប្រយុទ្ធគ្នាមានភាពខ្លាំងក្លាជាងគេនៅជុំវិញភ្នំវៃចាប ដែលជាកន្លែងលាក់ខ្លួនពួនអាត្មារបស់អតីតពួកមេបះបោរ និង ពួកអ្នកស្រុក(ដាច់ខាត)ដែលរត់គេចពីទាហាន លន់-នុលយកមកធ្វើជាជម្រករបស់គេ ។ ពួកអ្នកបះបោរត្រូវពួកអ្នកស្រុករាប់រយនាក់ដែលប្រដាប់ដោយកាំបិតពូថៅជាកងរក្សាសណ្តាប់ធ្នាប់ឲ្យទទួលបន្ទុក "ដេញពួកក្រហម" ដេញកាប់សម្លាប់ដល់ក្នុងព្រៃ ។ គេផ្តល់រង្វាន់ដល់អ្នកណាដែលបានកាត់ក្បាលជនរងគ្រោះយកមកឲ្យអាជ្ញាធរ ។ មានមនុស្សជាងមួយពាន់អ្នកដែលត្រូវបាត់បង់ជីវិតក្នុងពេលនោះ ។ អ្នកដែលនៅសេសសល់គេចផុតពីការកាប់សម្លាប់នោះមានកំហឹងពេញខ្លួនជាប់ជានិច្ច ។ ការកាប់សម្លាប់នេះមានលក្ខណៈប្រហាក់ប្រហែលនឹងការកាប់សម្លាប់នៅឥណ្ឌូស៊ីដែរ(គ្រាន់តែមានកម្រិតតូចជាង) ហើយមិនត្រូវគេផ្តន្ទាទោសទេ ។

សញ្ញាជាច្រើនបញ្ជាក់ថា សម្តេចចាប់ផ្តើមបាត់បង់អភិបាលកិច្ចលើរដ្ឋាភិបាលហើយ ។ មានក្រុមមនុស្ស ចចេចចចាចពី ស៊ូហារតូ និង ណាស៊ុសុនខ្មែរ ដោយធ្វើការប្រៀបធៀបទៅ នឹងរដ្ឋប្រហារដ៏បង្ហូរឈាម ដែលកើតឡើងនាឆ្នាំ ១៩៦៦នៅឥណ្ឌូស៊ី ។

ក្នុងស្ថានភាពបែបនេះ ពាក្យចោទប្រកាន់ប្រាសមកលើ លោកហ៊ុយ-នឹមនិងខ្ញុំថាជាមេក្លោងបះបោរ និងការគំរាមកំហែងចាប់ខ្លួនពួកយើងយកទៅកាត់ទោសនៅមុខតុលាការសឹកនោះ មិនអាចចាត់ទុកជារឿងលេងសើចបានទេ ។ យើងលែងមានអារម្មណ៍ថានឹងមានសន្តិសុខទៀតហើយ នៅភ្នំពេញ ។ ហេតុដូច្នេះហើយ ទើបយើងសម្រេចចិត្តយល់ព្រមតាមសំណូមពររបស់បក្សកុំម្មុយនិស្តកម្ពុជា ដែលសុំឲ្យពយកយើងរត់គេចទៅលាក់ខ្លួនទៅជនបទ ។ សំណូមពរនេះធ្វើតាមរយៈសំបុត្រមួយដែលមានការវិភាគសភាពការណ៍យ៉ាងល្អិតល្អន់ដែលគ្មានឲ្យយើងសង្ស័យអ្វីទេ ជាពិសេសទៅទៀតសំបុត្រនេះបានពាំនាំមកដល់យើងតាមរយៈមនុស្សដែលយើងទាំងពីរបានស្គាល់ច្បាស់ ។ គាត់គឺជាមនុស្សគួរឲ្យគោរពដោយចំណាស់របស់គាត់ក៏ដូចជាសមានចិត្តល្អរបស់គាត់ដែរ ។ គាត់ធ្លាប់បានចូលរួមយ៉ាងសកម្មក្នុងអង្គប្រជុំដែលរៀបចំឡើងដោយ “សមាគមមិត្តភាពនៃអតីតនិស្សិតវិទ្យាល័យស៊ីសុវត្ថិ” ជាហូរហែរ ដែលមានពួកយើងនៅក្នុងនោះដែរ ។ ដល់ពេលយប់កំណត់ជួប គាត់បានបើករថយន្តជូនពួកយើងតាមផ្លូវជាតិលេខ១៣ ហើយបាននាំយើងទៅដាក់នៅខាងកើត អង្គតាសោម ។ នៅទីនោះកសិករមួយក្រុមបានរង់ចាំយើងជាស្រេច ។

គួរគូសបញ្ជាក់នៅទីនេះថា ៖

១- ការដែលខ្ញុំបានចាកចេញពីភ្នំពេញនៅឆ្នាំ១៩៦៧នោះ គឺ ធ្វើឡើងដោយការបង្ខំចិត្ត ។ វាមិនមែនជា ការសម្រេចចិត្តដោយចេតនារបស់ខ្ញុំក្នុងការបោះបង់ចោលមុខតំណែង តំណាងរាស្ត្រដើម្បីជ្រើសរើសផ្លូវបដិវត្តិន៍នោះទេ ។

២- ចាប់ពីពេលនោះមក ខ្ញុំត្រូវបានធ្លាក់ក្នុងកំនួចព្យុះសង្ឃរានៃព្រឹត្តិការណ៍ ហើយត្រូវបានគាំពារដោយចលនាមួយដែលមិនឆ្លើយតប ជាអាទិ ទៅនឹង ការអប់រំរបស់ខ្ញុំ និង ទម្លាប់រស់នៅរបស់ខ្ញុំ ក្នុងខ្ញុំនាមជាបញ្ញាវ័ននិងជាតំណាងរាស្ត្រ ។ ខ្ញុំមិនអាចធ្វើអ្វី លើសពីព្យាយាមធ្វើប្រតិកម្មតបទៅនឹងឧប្បត្តិហេតុទាំងឡាយ ដោយខំរក្សាយ៉ាងខ្ជាប់ខ្ជួននូវលទ្ធភាព ដែលជាការបង្កាប់នៃអភិសមាចាររបស់ខ្ញុំ ។

# III
# Pourquoi ai-je été obligé de quitter Phnom Penh en 1967 ?

Au cours des années soixante, à travers des hauts et des bas, la tension ne cessa donc de monter, tant au sein de la société khmère qu'à l'extérieur du pays.

A l'intérieur du pays, la division entre les deux tendances de l'opinion publique, en particulier entre les partisans et les opposants à la politique de neutralité et &indépendance du Prince Norodom Sihanouk, ne cessait de s'accentuer, les difficultés économiques et sociales de s'aggraver. Dans les villes, l'industrie, qui n'avait jamais été importante, déclina, alors que la population ne cessait de gonfler, à la fois sous la pression de l'appauvrissement de la campagne et sous l'effet d'entraînement du niveau de style de -vie des couches supérieures de la société.

Pendant ce temps, l'escalade de la guerre au Vietnam accula le Prince dans une position de plus en plus difficile.

A partir de 1965, pour échapper aux opérations de nettoyage et de ratissage menées par les troupes américaines et sud-vietnamiennes, et aux attaques aériennes intensives, les troupes nord-vietnamiennes vinrent s'abriter dans certaines positions de notre territoire, le long de la frontière. Le Prince n'eut d'autre choix que de le tolérer. Un an plus tard, lorsque le blocus côtier et les bombardements américains sur la piste HoChi-Minh portèrent un coup sévère à leurs ravitaillements, il ne pouvait non plus refuser le transit des armes et munitions à leur destination par le port de Sihanoukville (Kampong Som). Ce devait être pour le Prince un risque calculé. Le soutien ainsi apporté en secret à Hanoi constituait une transgression indéniable à sa neutralité et n'allait pas manquer d'attirer sur lui de nouveaux ennuis à l'intérieur aussi bien qu'à l'extérieur du pays. Mais la préoccupation immédiate du Prince semblait être d'aider les résistants vietnamiens à mieux résister aux coups de boutoirs des Américains et d'empêcher ainsi la guerre de s'étendre trop en deçà de nos frontières. Le Prince pouvait également miser sur la résistance vietnamienne qui lui apparaissait déjà comme le futur vainqueur, pour obtenir en reconnaissance après la libération du Vietnam, une relation de bon voisinage et d'amitié entre nos deux pays et nos deux peuples.

Le malheur, c'est que le transit des armes et munitions destinées aux communistes vietnamiens par le port de Sihanoukville fut l'occasion d'un sale trafic qui acheva de déstabiliser notre économie déjà faible, par . une hémorragie de nos finances provoquée par la contrebande du riz et des denrées de première nécessité pour les deux belligérants de la guerre du Vietnam. Voici ce qu'a écrit William Shawcross au sujet de ce trafic :

« A partir de ce moment-là (1966), et jusqu'en 19 70, les cargaisons furent déchargées dans le port, puis transportées par l'armée cambodgienne et une société chinoise du nom de Ha Klee; les camions de marchandises parlaient de nuit sur la Route de l'amitié que les Etats-Unis avaient aidé à construire, traversaient Phnom Penh en direction de lEst, et se dirigeaient vers les régions frontalières. Cette affaire de transport, ainsi que l'achat par les communistes de nourriture et de médicaments directement sur le marché de Phnom Penh, se révélèrent extrêmement profitables' »

Et quelle ironie, Lon Nol, tout en couvrant le trafic (et probablement en y participant), travailla à se rallier non seulement de puissants groupes sociaux qui ne cachaient même plus leur nostalgie du temps de la vache grasse de l'aide américaine, mais encore des fonctionnaires d'État et l'élite intellectuelle qui étaient de plus en plus nombreux a se sentir frustrés par la corruption généralisée du pays, pour déclencher une véritable guerre souterraine contre le Prince : des critiques à peine voilées à son égard et des histoires des plus scandaleuses sur la corruption de la famille royale se propagèrent dans toute la capitale.

Et avec l'approche des élections pour le renouvellement de l'Assemblée Nationale, pendant que le Prince était assiégé par des centaines de requêtes pour solliciter son entérinement de la part de candidats en perspective, les critiques se précisèrent plus particulièrement sur son intervention personnelle dans le choix des candidats du Sangkum lors des élections antérieures.

©រក្សាសិទ្ធិគ្រប់យ៉ាង

http://www.amekhmer.org

C'est ainsi que le Prince s'abstint cette fois-ci d'intervenir et laissa la liste ouverte à tous les membres du mouvement. Peut-être était-il exaspéré par les critiques? Peut-être voulait-il éviter de s'aliéner certains de ses fidèles ? Dans pareille situation en effet, opter pour les uns revenait à rejeter les autres dans les rangs de ses adversaires. En tout cas, c'était de sa part une grave erreur, lourde de conséquences pour lui-même et pour le pays.

***William Shawcross, « Une tragédie sans importance », p. 58***

En effet, à l'abri du « Sangkum » et sous le prétexte de la lutte anticommuniste, Lon Nol s'attachait depuis un certain temps déjà à préparer à l'insu du Prince sa propre ascension au pouvoir. Il ralliait à lui la plupart des chefs de provinces, des chefs de districts et de communes. En réalité, l'assemblée issue des élections «libres » de cette année 1966 fut un instrument entre ses mains. C'est elle qui, quatre ans plus tard, votera la déposition du Prince.

En attendant, Lon Nol, alors devenu Premier Ministre, obtint l'accord du Prince pour une proposition visant à former des «comités gouvernementaux pour le ramassage du paddy' », soi-disant pour lutter contre la contrebande et mettre fin à l'hémorragie des finances. En fait ces comités servirent plutôt à couvrir tout un appareil, mis en place depuis déjà des années, pour intensifier la répression.

La plus brutale eut lieu à Samlot 2 , dans la province de Battambang, alors que les paysans protestaient contre l'expropriation de leurs terres par des chefs militaires.

A ce propos, voici ce qu'écrit William Shaw Cross : « La répression fut sanglante, des villages furent rasés et les paysans battus à mort. Des centaines d'entre eux prirent le maquis, révoltés àjamais » 3

David P. Chandler relate quant à lui ainsi les évènements:

*1 Paddy est le nom donné au riz lorsqu'il n'est pas encore décortiqué.*
*2 Par Samlot, on entendait la région englobant à la fois le chef-lieu actuel du district et les villages situés le long de la route n' 10, jusqu'à Kompong Kol et Andoeuk Hep, à l'ouest de Battambang..*
*3 William Shaw Cross, « une tragédie sans importance» - p. 247.*

"L'opération de nettoyage autour de Samlot continua plusieurs mois. Le combat fut particulièrement acharné autour de la montagne Vay Chap, unecachette désanci . ens guéri1leros, réoccupée récemment par les radicaux qui fuyaient Lon Nol. Les rebelles étaient poursuivis dans la forêt par des centaines d'hommes de la région que l'on avait munis de bâtons et de hachettes, et groupés en milices chargées de "chasser les rouges"  Des récompenses étaient données à ceux qui rapportaient aux autorités des têtes coupées. Plus d'un millier de victimes ont perdu la vie. Beaucoup de survivants sont restés révoltés à jamais... La tuerie se rapproche des massacres dIndonésie (bien qu'à une échelle réduite) par son caractère de règlement de compte contre les "communistes", et le fait de demeurer impunie 'fi

Bien des signes indiquaient que le Prince commençait à perdre le contrôle du gouvernement. Déjà, par petits groupes, on parlait d'un Souharto et d'un Nassusson cambodgiens, en faisant allusion au coup d'État sanglant survenu en mars 1966 en Indonésie.

Dans de telles circonstances, l'accusation lancée à l'encontre* de Hou Youn 2 et de moi-même d'être à l'origine de la révolte et la menace de nous faire comparaître devant un tribunal militaire ne pouvaient être prises à la légère. Nous ne nous sentions plus en sécurité à Phnom Penh. C'est ainsi que nous acceptâmes la proposition du Parti

*1-David P. Chandler, Frère numéro un, p. 78, édition révisée, Silkworms books.*
*2-Hou Youn était un de ces "intellectuels de gauche" qui avait fait ses études de droit à Paris. Il était parmi les étudiants dont la bourse avait été coupée pour raison politique. Il parvenait cependant à poursuivre ses études jusqu'à la la De retour au Cambodge, il adhéra au Sangkum, et se fit élire comme député dans la circonscription de Pearn Chikâng (Kompong Cham).*

Communiste du Kampuchéa (P.C.K.) de partir nous mettre à l'abri à la campagne. La proposition nous a été faite dans une lettre qui comportait une analyse assez détaillée de la situation, de façon à ne nous laisser aucun doute sur les expéditeurs, d'autant plus que le messager qui nous l'avait

apportée était bien connu de nous deux. C'était un homme respecté à la fois par son âge et sa prévenance. Il participait activement aux rencontres organisées par l'amicale des Anciens Elèves du Lycée Sisovath, dont nous faisions également partie. A la nuit convenue, il nous conduisit sur la route n°3 pour nous déposer un peu à l'est de Ang-Tasomm. Là nous attendait un groupe de paysans.

Il convient de souligner ici que :

l' Si j'ai été amené à quitter Phnom Penh en 1967, c'était bien par la force des choses. Ce n'était pas de ma part une décision délibérée d'abandonner mes activités parlementaires pour m'engager dans la voie de la lutte révolutionnaire.

2' A partir de ce moment, emporté par les tourbillons des événements, protégé par un mouvement qui ne correspondait a priori ni à ma formation ni à mes options de vie comme intellectuel et parlementaire, je n'ai pu que tenter de réagir face aux multiples péripéties en préservant au mieux des possibilités ce que me dictait mon éthique.

©រក្សាសិទ្ធិគ្រប់យ៉ាង
http://www.amekhmer.org